## តំបន់តភ្ជាប់ (Contiguous Zone)

- តំបន់តភ្ជាប់គឺជាតំបន់សមុទ្រដែលបន្តពីសមុទ្រដែនដី១២ម៉ែល៍សមុទ្របន្ថែមទៀតពោលគឺលាតសន្ធឹងទៅឯនាយសមុទ្រមិនលើសពី២៤ម៉ែល៍សមុទ្រពីខ្សែបន្ទាត់មូលដ្ឋាន។ ទទឹងនេះ ក៏ត្រូវបានគិតពីខ្សែបន្ទាត់មូលដ្ឋាន។ តំបន់នេះ ជាន់គ្នានឹងផ្នែកខ្លះនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ។

**មាត្រា៣៣នៃអនុសញ្ញា** UNCLoS **ឆ្នាំ១៩៨២៖**

១. ក្នុងតំបន់ដែលជាប់សមុទ្រដែនដីហៅថាតំបន់តភ្ជាប់ រដ្ឋជាប់ឆ្នេរសមុទ្រអាចធ្វើការគ្រប់គ្រងដែលចាំបាច់ដើម្បី៖

(ក) បង្ការការរំលោភបំពានលើច្បាប់ និងបទបញ្ជាផ្នែកគយ សារពើពន្ធ អន្តោប្រវេសន៍ អនាម័យក្នុងដែនដី ឬសមុទ្រដែនដីរបស់រដ្ឋនោះ។

(ខ) ផ្តន្ទាទោសលើការរំលោភបំពានច្បាប់ និងបទបញ្ជាខាងលើ ដែលបានប្រព្រឹត្តក្នុងដែនដី ឬសមុទ្រដែនដីរបស់ខ្លួន។

២. តំបន់តភ្ជាប់មិនអាចមានចម្ងាយលើសពី២៤ ម៉ាយល៍ពីខ្សែបន្ទាត់មូលដ្ឋាន សម្រាប់វាស់ប្រវែងសមុទ្រដែនដីបានឡើយ។

-ក្នុងតំបន់នេះ រដ្ឋជាប់ឆ្នេរមិនមានអធិបតេយ្យ តែមានសិទ្ធិអធិបតេយ្យ មានត្រឹមតែយុត្តាធិការក្នុងកម្រិតមួយ ដើម្បីទប់ស្កាត់ការបំពាន ឬបទល្មើសដែលកើតក្នុងសមុទ្រដែនដីនិងដែនដី។

- រដ្ឋជាប់ឆ្នេរ ត្រូវគោរពសេរីភាពនាវាចររបស់រដ្ឋដទៃ។

-សិទ្ធិនេះត្រូវបានអនុវត្តដូចគ្នានៅក្នុងសមុទ្រដែនដីដែរដូចជាពាក់ព័ន្ធនឹងបទល្មើសគយសារពើពន្ធ ការឆ្លងដែន ឬបញ្ហាអនាម័យ រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

-រដ្ឋជាប់ឆ្នេរអាចធ្វើការដេញចាប់ (hot pursuit) នាវាបរទេសចេញពីតំបន់នេះ និងអាចបន្តដេញនៅខាងក្រៅសមុទ្រដែនដីឬតំបន់តភ្ជាប់នេះបាន ប្រសិនបើការដេញនេះបន្តជាប់ គ្មានមិនបង្អាក់ (UNCLoS, មាត្រា១១១)។

-រដ្ឋដទៃមានសេរីភាពនាវាចរនិងហោះហើរលើតំបន់នេះដែរ។

**កំណត់សំគាល់៖** ភាពខុសគ្នារវាងអធិបតេយ្យ (sovereignty) និងសិទ្ធិអធិបតេយ្យ (sovereign rights)។ អធិបតេយ្យ សំដៅលើអំណាចធ្វើច្បាប់ អនុវត្តច្បាប់ និងអនុវត្តយុត្តាធិការ ខណៈដែលសិទ្ធិអធិបតេយ្យមានលក្ខណៈចង្អៀតជាង អធិបតេយ្យ។